## សំណួរ និង ចម្លើយ ស្តីពី ពាក់ព័ន្ធនឹងច្បាប់

## សំណួរៈ តើការដាក់ប្រទេសក្នុងស្ថានភាពអាសន្ន តម្រូវឲ្យគោរពនីតិវិធី និងលក្ខខណ្ឌអ្វីខ្លះ?

១.មាត្រា ៤ នៃកតិកាស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ http://www.measboralaws.com/detail/307 បានចែងអំពី គ្រោះអាសន្នសាធារណៈ និងសិទ្ធិដែលអាចត្រូវបានកម្រិត។ តាមខ្លឹមសារ គ្រោះអាសន្នទំនងជាធ្ងន់ធ្ងរ ប្រសិន បើយើងពិនិត្យមើលពាក្យ «អាសន្នជាសាធារណៈពិសេស ដែលគំរាមកំហែងដល់អត្ថិភាពជាតិ»។ នេះ ដោយសារថា ការដាក់ប្រទេសក្នុងភាពអាសន្ន ក្រៅពីប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ វិធានការដែលនឹងត្រូវប្រើ អាចប៉ះដល់បុគ្គល។ វិធានការនោះរួមបញ្ចូលនូវការកម្រិតសិទ្ធិ (restriction of rights) ដែលតម្រូវដោយភាពចាំបាច់ និង ឲ្យគោរពនូវគោលការណ៍ចម្បងមួយចំនួន។ សិទ្ធិជាវិធាន ហើយការកម្រិតជា ករណីលើកលែង។

២. មាត្រា ៤ ចែងទាំងសារធាតុ និងនីតិវិធីចម្បងមួយចំនួន។ ជាសារធាតុ មាត្រាចែងអនុញ្ញាតឲ្យកម្រិតសិទ្ធិមួយចំនួន តាមករណីជាចាំបាច់តម្រូវតាមស្ថានភាព។ ក៏ប៉ុន្តែ សិទ្ធិខ្លះជាសិទ្ធិដាច់ខាត (non-derogable rights) http://www.measboralaws.com/detail/796 មិនត្រូវអនុញ្ញាតឲ្យផ្អាក ឬ កម្រិតទេ ដូចជាសិទ្ធិរួចផុតពីអំពើទារុណកម្ម (កថាខ័ណ្ឌទី២)។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិមួយចំនួន មិនត្រូវរាប់ចូលជាសិទ្ធិដាច់ខាតក្នុងមាត្រានេះ ត្រូវបានកំណត់ថា មិនត្រូវបានអនុញ្ញាតឲ្យផ្អាក ឬកម្រិតផងដែរ ដូចជាសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ http://www.measboralaws.com/detail/350។ នេះដើម្បីជួយធានាការពារតាមផ្លូវតុលាការ បង្ការកុំឲ្យអាជ្ញាធរប្រតិបត្តិបំពារបំពានសិទ្ធិធ្ងន់ធ្ងរ តាមទំនើងចិត្ត។

៣. វិធានការ មិនត្រូវមានចរិតរើសអើង http://www.measboralaws.com/detail/821 ហើយមិនត្រូវបំពានកាតព្វកិច្ចអន្តរជាតិដទៃទៀត។ ឧទាហរណ៍ ការកម្រិតសិទ្ធិលើក្រុមមនុស្សមួយ តែមិនកម្រិតសិទ្ធិក្រុមមនុស្សផ្សេងដោយគ្មានហេតុផល។ ទោះបីនៅក្នុងស្ថានភាពគ្រោះអាសន្ន ការសម្លាប់មនុស្ស អាចត្រូវបានអនុញ្ញាត ក៏ប៉ុន្តែការសម្លាប់រង្គាលក្នុងចេតនា បំបាត់ពូជសាសន៍ នឹងបំពានទូវកាតព្វកិច្ចចែងនៅក្នុងអនុសញ្ញា ស្តីពី ការប្រឆាំងនឹងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ និងត្រូវបានហាមឃាត់ http://www.measboralaws.com/detail/207។

៤. គ្រោះអាសន្ន ត្រូវតែប្រកាសជាសាធារណៈ និងត្រូវជូនដំណឹងជាបន្ទាន់ទៅរដ្ឋជាភាគីដទៃទៀតនៃកតិកាសញ្ញា តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទប្បញ្ញត្តិដែលត្រូវកម្រិត និងមូលហេតុ។ ការបញ្ចប់ភាពអាសន្ន ក៏ត្រូវធ្វើដូចនីតិវិធីដដែលនេះ (មាត្រា ៤)។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានចេញនូវយោបល់ទូទៅ ស្តីពី គ្រោះអាសន្នសាធារណៈ ក្នុងមាត្រា ៤ នេះ http://www.measboralaws.com/detail/1085 ។